ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
លេខ: ៥៧ អយក.ណណន

# សេចក្ដីណែនាំ
# ស្ដីពី
# ដំណើរការបង្រៀន និងរៀនពេញមួយថ្ងៃ
# សម្រាប់គ្រឹះស្ថានមធ្យមសិក្សាចំណេះទូទៅសាធារណៈ

ក្រសួងអប់រំ យុវជន និងកីឡាបាននឹងកំពុងអនុវត្តកំណែទម្រង់ការគ្រប់គ្រងសាលារៀនយ៉ាងសកម្មតាមរយៈការលើកទឹកចិត្តឱ្យគណៈគ្រប់គ្រងសាលារៀន គ្រូបង្រៀន ក្នុងការបង្កើនស្វ័យភាព គណនេយ្យភាព និងភាពជាអ្នកដឹកនាំក្នុងការគ្រប់គ្រងសេវាអប់រំនៅកម្រិតសាលារៀន។ ការរៀបចំឱ្យមានដំណើរការបង្រៀន និងរៀនពេញមួយថ្ងៃ ជាការឆ្លើយតបទៅនឹងតម្រូវការពិតប្រាកដរបស់សហគមន៍ មាតាបិតា ឬអ្នកអាណាព្យាបាល នាពេលបច្ចុប្បន្ន និងការបង្ហាញពីលទ្ធផលសិក្សារបស់សិស្សមានការរីកចម្រើនជាប្រចាំ ជាក់ស្ដែង និងជឿទុកចិត្តបាន។ ដូចនេះ គ្រឹះស្ថានមធ្យមសិក្សាចំណេះទូទៅ ដែលមានធនធានគ្រប់គ្រាន់អាចដំណើរការកម្មវិធីបង្រៀន និងរៀនពេញមួយថ្ងៃ ត្រូវអនុលោមតាម៖

## ១. ការគ្រប់គ្រង និងការទ្រទ្រង់ដំណើរការ

### ១.១. មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត និងការិយាល័យអប់រំ យុវជន និងកីឡា នៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ

- សម្របសម្រួលការចូលរួមគាំទ្រពីអាជ្ញាធរមូលដ្ឋាន សហគមន៍ មាតាបិតា ឬអ្នកអាណាព្យាបាលសិស្ស និងគ្រូបង្រៀនព្រមទាំងកៀរគរធនធាននានាក្នុងកិច្ចដំណើរការសាលារៀនឱ្យមានប្រសិទ្ធភាព
- រៀបចំផែនការប្រតិបត្តិប្រចាំឆ្នាំ សម្រាប់គ្រប់គ្រងដំណើរការ នៃការអនុវត្តការបង្រៀន និងរៀនពេញមួយថ្ងៃ
- តាមដាន និងត្រួតពិនិត្យការអនុវត្តកម្មវិធីសិក្សា និងកាលវិភាគប្រចាំសប្ដាហ៍របស់គ្រឹះស្ថានមធ្យមសិក្សាចំណេះទូទៅ
- ជំរុញការបង្រៀន និងរៀនតាមគ្រឹះស្ថានមធ្យមសិក្សាចំណេះទូទៅឱ្យបញ្ចប់កម្មវិធីសិក្សានូវគ្រប់កម្រិតថ្នាក់ និងគ្រប់មុខវិជ្ជាប្រកបដោយគុណភាព
- រៀបចំយន្តការធ្វើតេស្តវាយតម្លៃសិស្សតាមគ្រឹះស្ថានមធ្យមសិក្សាចំណេះទូទៅ ដើម្បីវាយតម្លៃលទ្ធផលសិក្សារបស់សិស្សដើមឆ្នាំ ប្រចាំខែ ប្រចាំឆមាស និងដំណាច់ឆ្នាំសិក្សា
- តាមដាន និងក្ដាប់ឱ្យបានច្បាស់លាស់ អំពីលទ្ធផលសិក្សារបស់សិស្សប្រចាំខែ ប្រចាំឆមាស និងដំណាច់ឆ្នាំ
- បូកសរុប និងវាយតម្លៃការរីកចម្រើន និងផលប៉ះពាល់នៃការអនុវត្តកម្មវិធីបង្រៀននិងរៀនពេញមួយថ្ងៃ ដើម្បីធ្វើការកែលម្អ និងចងក្រងឯកសារមេរៀនពិសោធន៍ពីការអនុវត្ត ការបង្រៀន និងរៀនពេញមួយថ្ងៃ។

### ១.២. គ្រឹះស្ថានមធ្យមសិក្សាចំណេះទូទៅ

គណៈគ្រប់គ្រងសាលារៀន ត្រូវបង្ហាញឱ្យឃើញពីការទាមទាររបស់សហគមន៍ មាតាបិតា ឬអ្នកអាណាព្យាបាល ដែលជាអ្នកគាំទ្រ និងចូលរួមទាំងស្រុង ក៏ដោយសារតែសាលារៀនបានយកចិត្តទុកដាក់ និងប្តេជ្ញាចិត្តអនុវត្តឱ្យសម្រេចស្តង់ដាសាលារៀនគំរូ។ ដូចនេះ ការរៀបចំអនុវត្តកម្មវិធីរៀនពេញមួយថ្ងៃ គឺជាបរិបទនៃការផ្លាស់ប្តូរពីការរៀនតែមួយពេល និងជាតម្រូវការរបស់សហគមន៍សាលារៀន។

#### ១.២.១. ម៉ោងសិក្សា

- គ្រឹះស្ថានមធ្យមសិក្សាចំណេះទូទៅត្រូវកំណត់ម៉ោងសិក្សាដោយពេលព្រឹកចូលម៉ោង ៧:០០ ចេញម៉ោង ១១:០០ និងរសៀលចូលម៉ោង ១៣:០០ ឬម៉ោង ១៤:០០ ចេញម៉ោង ១៦:០០ ឬម៉ោង ១៧:០០
- គ្រឹះស្ថានមធ្យមសិក្សាចំណេះទូទៅត្រូវរៀបចំកាលវិភាគបង្រៀនឱ្យបានយ៉ាងតិច ៤០ម៉ោងសិក្សាក្នុងមួយសប្តាហ៍ដែល ១ម៉ោងសិក្សាមានរយៈពេល៥០នាទី និងលម្អិតទៅតាមកម្រិតថ្នាក់ និងមុខវិជ្ជា។

#### ១.២.២.ការដឹកនាំ និងគ្រប់គ្រងរដ្ឋបាលសាលារៀន

ការធ្វើឱ្យសាលារៀន និងថ្នាក់រៀនមានការផ្លាស់ប្តូរ គឺផ្តោតលើការជួយសិស្សរៀនយឺត សិស្សរៀនលឿន រៀនទាន់តាមកម្រិតថ្នាក់ ដែលនាំឱ្យសហគមន៍ មាតាបិតា ឬអ្នកអាណាព្យាបាល ពេញចិត្ត និងជួយគាំទ្រដល់សាលារៀន។ ដូចនេះ គណៈគ្រប់គ្រងសាលារៀនត្រូវ៖

- រៀបចំបែងចែកតួនាទី ភារកិច្ចទទួលខុសត្រូវរបស់គណៈគ្រប់គ្រងសាលារៀន គ្រូបង្រៀន គណៈកម្មការគ្រប់គ្រងសាលារៀន និងគ្រប់អ្នកពាក់ព័ន្ធក្នុងការអនុវត្តការបង្រៀន និងរៀនពេញមួយថ្ងៃ ឱ្យសមស្របតាមជំនាញ និងសមត្ថភាព ដើម្បីធានាបាននូវប្រសិទ្ធភាពដំណើរការបង្រៀន និងរៀនពេញមួយថ្ងៃ
- រៀបចំផែនការសកម្មភាពសម្រាប់គ្រប់គ្រងដំណើរការនៃការអនុវត្តការបង្រៀន និងរៀនពេញមួយថ្ងៃដោយផ្អែកតាមផែនការកែលម្អសាលារៀន បញ្ចូលការបណ្តុះបណ្តាលជាប្រចាំស្តីពីវិធីសាស្ត្របង្រៀនថ្មីៗ ការប្រើប្រាស់បច្ចេកវិទ្យា និងការគ្រប់គ្រងថ្នាក់រៀនឱ្យមានប្រសិទ្ធភាព
- គ្រប់គ្រងធនធាន និងថវិកាសម្រាប់អនុវត្តការបង្រៀន និងរៀនពេញមួយថ្ងៃឱ្យមានគណនេយ្យភាព និងតម្លាភាព
- រៀបចំដំណើរការថ្នាក់រៀន មានបន្ទប់កុំព្យូទ័រ បន្ទប់ពិសោធន៍ និងបន្ទប់មុខវិជ្ជា ឱ្យបានស្អាត មានខ្យល់ចេញចូលគ្រប់គ្រាន់ មានពន្លឺគ្រប់គ្រាន់ និងមានបំពាក់សម្ភារៈសិក្សាតាមលទ្ធភាព
- រៀបចំឱ្យមានសកម្មភាពបំណិនជីវិតមូលដ្ឋាន ដូចជាដាំដុះក្នុងសួនបន្លែសាលារៀន
- រៀបចំឱ្យមានសកម្មភាពច្នៃប្រឌិតការប្រើប្រាស់ឡើងវិញនូវសម្ភារៈ ឬសំណល់ផ្ទះបាយជាជីកំប៉ុស្តបម្រើឱ្យសួនបន្លែ ឬសួនជីវៈចម្រុះសាលារៀន
- រៀបចំកម្មវិធីកៀរគរការឧបត្ថម្ភ ការសហការ និងការចូលរួមពីសហគមន៍ អាជ្ញាធរដែនដី អង្គការសប្បុរសជននានា សម្រាប់ការគាំទ្រដល់ការអនុវត្តការបង្រៀន និងរៀនពេញមួយថ្ងៃ
- ស្វែងរកដៃគូ ឬអ្នកស្ម័គ្រចិត្តជួយបង្រៀនលើមុខវិជ្ជាចាំបាច់ ដែលបានបន្ថែមក្នុងកម្មវិធីសិក្សាដើម្បីឱ្យកម្មវិធីទាំងនេះមានដំណើរការប្រកបដោយប្រសិទ្ធភាព
- រៀបចំប្រព័ន្ធវាយតម្លៃការអនុវត្តការងាររបស់គ្រូបង្រៀនជាប្រចាំ និងផ្តល់មតិកែលម្អប្រកបដោយការស្ថាបនា។

#### ១.២.៣. ការគ្រប់គ្រងបច្ចេកទេសបង្រៀន និងរៀន

ភាសាខ្មែរ គណិតវិទ្យា ភាសាបរទេស និងមុខវិជ្ជាមួយចំនួនទៀត ដែលអាចបត់បែនការអនុវត្ត ឬតាមស្ថានភាពជាក់ស្តែងរបស់សាលារៀន ព្រមទាំងជួយសិស្សរៀនយឺតផងដែរ។ ប្រសិនបើមានលទ្ធភាពអាចបញ្ចូលការអនុវត្តកម្មវិធីសិក្សាទំនើប ដោយបន្ថែមមុខវិជ្ជាភាសាអង់គ្លេស ចិន កុំព្យូទ័រ ការអប់រំស្ទែមរ៉ូបូទិក ការអប់រំសិល្បៈ កីឡា...

- រៀបចំបំណែងចែកកម្មវិធីសិក្សា ដោយបែងចែកចំនួនម៉ោង និងចំនួនមេរៀនបង្រៀនតាមសប្តាហ៍ និងតាមខែសម្រាប់អនុវត្តការបង្រៀន និងរៀនពេញមួយថ្ងៃទៅតាមកម្រិតថ្នាក់
- តាមដាន និងត្រួតពិនិត្យការអនុវត្តកម្មវិធីសិក្សា និងកាលវិភាគប្រចាំសប្តាហ៍ទៅតាមកម្រិតថ្នាក់ ដោយបូកសរុបលទ្ធផលរៀងរាល់សប្តាហ៍ទីបួននៃខែនីមួយៗ
- ជំរុញការបញ្ចប់កម្មវិធីសិក្សាគ្រប់កម្រិតថ្នាក់ និងគ្រប់មុខវិជ្ជាប្រកបដោយគុណភាពនៅដំណាច់ឆ្នាំសិក្សា
- ពិនិត្យ និងកែលម្អកិច្ចតែងការបង្រៀនរបស់គ្រូជាប្រចាំ
- តាមដាន និងវាយតម្លៃលទ្ធផលសិក្សារបស់សិស្សតាមមុខវិជ្ជា ប្រចាំខែ និងត្រីមាស ដើម្បីជួយសិស្សរៀនយឺតឱ្យបានទាន់ពេលវេលា
- រៀបចំឱ្យគ្រូបង្រៀន មានកម្មវិធី និងផែនការជួយសិស្សរៀនយឺត
- ចូលរួម និងរៀបចំការធ្វើតេស្តវង្វាយតម្លៃលទ្ធផលសិក្សាសិស្ស ដើម្បីវាយតម្លៃលទ្ធផលសិក្សារបស់សិស្សប្រចាំខែ ប្រចាំឆមាស និងដំណាច់ឆ្នាំសិក្សា
- បូកសរុប និងវាយតម្លៃការរីកចម្រើន និងផលប៉ះពាល់នៃការជួយសិស្សរៀនយឺតតាមខែ និងតាមកម្រិតថ្នាក់នៅរៀងរាល់សប្តាហ៍ទីបួននៃខែនីមួយៗ
- ប្រជុំផ្សព្វផ្សាយដល់អ្នកពាក់ព័ន្ធ និងសិក្សារកឱ្យឃើញនូវមូលហេតុដែលនាំឱ្យសិស្សធ្លាក់មធ្យមភាគប្រចាំខែតាមកម្រិតថ្នាក់ ដើម្បីចាត់វិធានការជួយសិស្សឱ្យបានទាន់ពេលវេលា និងមានប្រសិទ្ធភាព
- រៀបចំផែនការពិនិត្យតាមដានការបង្រៀន និងរៀនតាមថ្នាក់ ដើម្បីធានាការអនុវត្តឱ្យបានត្រឹមត្រូវដោយរាយការណ៍ពីលទ្ធផលនៃការពិនិត្យតាមដាន និងផ្តល់អនុសាសន៍ដល់គ្រូបង្រៀនដើម្បីកែលម្អ
- រៀបចំប្រជុំបច្ចេកទេសតាមមុខវិជ្ជា ដើម្បីពិភាក្សាអំពីដំណើរការដែលទាក់ទងទៅនឹងការបង្រៀននិងរៀនពេញមួយថ្ងៃ ដូចជា ការរៀបចំកិច្ចតែងការបង្រៀន ការផលិតសម្ភារៈបង្រៀន ការរៀបចំថ្នាក់និទស្សន៍ និងការងារពាក់ព័ន្ធនានា។

### ១.២.៤. គ្រូបង្រៀន

- អភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ ដោយសិក្សាស្រាវជ្រាវដើម្បីបង្កើនចំណេះដឹង និងជំនាញជាប្រចាំ ដូចជាការរៀនភាសាបរទេស ការរៀនព័ត៌មានវិទ្យា និងការផ្លាស់ប្តូរបទពិសោធន៍
- ធ្វើជាគំរូល្អសម្រាប់សិស្ស ទាំងផ្នែកចំណេះដឹង សីលធម៌ និងឥរិយាបថរស់នៅប្រចាំថ្ងៃ និងត្រូវរក្សាសុខភាពល្អទាំងផ្លូវកាយ និងផ្លូវចិត្ត រក្សាបានកម្លាំងគ្រប់គ្រាន់ក្នុងការបង្រៀន
- សិក្សាឱ្យបានច្បាស់ពីស្ថានភាពគ្រួសារ សមត្ថភាព អាកប្បកិរិយា និងចំណង់ចំណូលចិត្តរបស់សិស្សានុសិស្ស
- យកចិត្តទុកដាក់ខ្ពស់ និងមានទំនាក់ទំនងល្អជាមួយសិស្សដើម្បីយល់ពីតម្រូវការ និងបញ្ហារបស់សិស្សម្នាក់ៗ
- សហការជាមួយមាតាបិតាសិស្ស ឬអ្នកអាណាព្យាបាល និងសហគមន៍ ដើម្បីគាំទ្រដល់ការសិក្សារបស់សិស្ស
- គ្រប់គ្រងបញ្ជីឈ្មោះសិស្ស បញ្ជីពិន្ទុ សៀវភៅតាមដានសិស្ស និងបញ្ជីជួយសិស្សរៀនយឺត

- គ្រប់គ្រងវត្តមាន និងតាមដានសិស្សអវត្តមានឱ្យបានច្បាស់លាស់ដោយដឹងពីមូលហេតុដើម្បីមានវិធានការ ឬទំនាក់ទំនងទៅមាតាបិតា ឬអាណាព្យាបាលតាមរយៈសៀវភៅទំនាក់ទំនង ឬទូរសព្ទ
- អនុវត្តកម្មវិធីសិក្សា និងកាលវិភាគឱ្យបានត្រឹមត្រូវ ចំពោះមុខវិជ្ជាពលរដ្ឋវិជ្ជា ត្រូវបង្រៀនខ្លឹមសារដែលទាក់ទងទៅនឹងសុជីវធម៌ និងសីលធម៌ដោយផ្សារភ្ជាប់ជីវភាពជាក់ស្តែង ឱ្យចេះរួមរស់ជាមួយគ្នា ប្រកាន់ខ្ជាប់នូវអំពើអហិង្សា ទំនៀមទម្លាប់ប្រពៃណីខ្មែរ ព្រះពុទ្ធសាសនា ឬសមាធិ...
- រៀបចំកិច្ចតែងការបង្រៀនលម្អិតតាមម៉ោងសិក្សា ទៅតាមកាលវិភាគសិក្សាឱ្យសមស្របទៅនឹងការបង្រៀន និងរៀនពេញមួយថ្ងៃ តាមកម្មវិធីសិក្សារបស់ក្រសួងអប់រំ យុវជន និងកីឡា
- រៀបចំដំណើរការសិក្សាបែបគម្រោង សិក្សាស្រាវជ្រាវ និងបណ្តុះទម្លាប់សិស្សក្នុងការធ្វើបទបង្ហាញ និងកាន់កម្មវិធីនានា
- ដឹកនាំសកម្មភាពបង្រៀន និងរៀនអនុវត្តតាមគោលវិធីសាស្ត្របង្រៀនថ្មីដោយប្រើប្រាស់សំណួរតាមកម្រិតប្លូមស្របតាមខ្លឹមសារមេរៀន
- ជ្រើសរើសវិធីសាស្ត្របង្រៀនឱ្យសមស្របនឹងខ្លឹមសារមេរៀន និងកម្រិតយល់ដឹងរបស់សិស្ស ដើម្បីឱ្យសិស្សងាយយល់ និងចូលរួមយ៉ាងសកម្ម ដោយបញ្ចូលការបង្រៀននិងរៀនដែលមានការប្រើប្រាស់បច្ចេកវិទ្យា និងវិធីសាស្ត្រប្រកបដោយភាពច្នៃប្រឌិត
- ណែនាំ និងដឹកនាំសិស្សឱ្យយល់ពីគោលបំណង និងខ្លឹមសារមេរៀន ដើម្បីឱ្យសិស្សសម្រេចបាននូវវត្ថុបំណងមេរៀន
- ផលិត និងប្រើប្រាស់សម្ភារឧបទេសឱ្យសមស្របទៅតាមខ្លឹមសារមេរៀនសម្រាប់ការបង្រៀន និងរៀនពេញមួយថ្ងៃ
- បង្កើតបរិយាកាសសិក្សាវិជ្ជមានដោយធានាឱ្យបាននូវបរិយាកាសសិក្សាក្នុងថ្នាក់រៀនមានភាពកក់ក្តៅ រួសរាយរាក់ទាក់ និងលើកទឹកចិត្តដល់ការរៀនសូត្រ ដែលគ្រូបង្រៀនគួរមានចិត្តត្រជាក់ មិនឆេវឆាវ និងពេញចិត្តចំពោះការបង្រៀន
- រៀបចំតេស្តវង្វាយតម្លៃ និងធ្វើការវាយតម្លៃលទ្ធផលសិក្សារបស់សិស្សតាមមុខវិជ្ជា និងតាមកម្រិតថ្នាក់ជាប្រចាំខែ ប្រចាំឆមាស និងប្រចាំឆ្នាំសិក្សាដើម្បីតាមដានវឌ្ឍនភាពនៃលទ្ធផលសិក្សារបស់សិស្ស
- ផ្តល់កម្លាំងចិត្ត និងលើកទឹកចិត្តសិស្សឱ្យចូលរួមសកម្មភាពក្នុងការសិក្សាទាំងក្នុងថ្នាក់ និងក្រៅថ្នាក់ដោយអាចធ្វើឡើងតាមរយៈការសរសើរ ការផ្តល់រង្វាន់ ឬការបង្ហាញពីសារៈសំខាន់នៃការសិក្សា
- ផ្តល់មតិកែលម្អដល់សិស្សប្រកបដោយការស្ថាបនា ដើម្បីឱ្យសិស្សយល់ពីចំណុចខ្លាំង និងចំណុចគួរកែលម្អរបស់ខ្លួន ដែលជំរុញឱ្យការសិក្សាបានកាន់តែល្អប្រសើរ
- បូកសរុប និងវាយតម្លៃការរីកចម្រើន ផលប៉ះពាល់នៃការជួយសិស្សរៀនយឺតជូនគណៈគ្រប់គ្រងសាលារៀននៅរាល់មុនដំណាច់ខែ។

**១.៣ គណៈកម្មការគ្រប់គ្រងសាលារៀន សហគមន៍ និងអ្នកពាក់ព័ន្ធ**

- គាំទ្រលើកិច្ចការមួយចំនួនតាមការស្នើសុំរបស់គណៈគ្រប់គ្រងសាលារៀន
- ជំរុញ និងផ្សព្វផ្សាយការអនុវត្តកម្មវិធីការបង្រៀន និងរៀនពេញមួយថ្ងៃឱ្យបានទូលំទូលាយដល់គ្រប់អ្នកពាក់ព័ន្ធ
- ចូលរួមបំផុសចលនាមូលនិធិសមធម៌ សម្រាប់អនុវត្តកម្មវិធីការបង្រៀន និងរៀនពេញមួយថ្ងៃ

- ផ្សព្វផ្សាយ និងអប់រំមាតាបិតាសិស្ស ឱ្យយល់ពីផលប្រយោជន៍នៃការសិក្សាពេញមួយថ្ងៃ ដើម្បីជួយតាមដាន និងជំរុញការរៀនសូត្ររបស់កូន ឱ្យទៅរៀនទាំងព្រឹក និងរសៀល
- ចូលរួមស្វែងរកដៃគូ ឬអ្នកស្ម័គ្រចិត្តបង្រៀនលើមុខវិជ្ជាចាំបាច់ ដែលបានបន្ថែមលើកម្មវិធីសិក្សា
- ចូលរួមទប់ស្កាត់បាតុភាពមិនប្រក្រតី និងដោះស្រាយបញ្ហានានាដែលកើតឡើងនៅក្នុង និងក្រៅសាលារៀន
- ចូលរួមក្នុងការសាងសង់ ជួសជុល និងថែរក្សាហេដ្ឋារចនាសម្ព័ន្ធរបស់សាលារៀន
- ចូលរួមលើកកម្ពស់ការងារសុខភាពលើផ្នែកអនាម័យចំណីអាហារ និងទប់ស្កាត់ជំងឺនានា
- ចូលរួមពិនិត្យតាមដាន និងវាយតម្លៃ លើការអនុវត្តការបង្រៀន និងរៀនពេញមួយថ្ងៃ
- ចូលរួមផ្តល់យោបល់ក្នុងការចងក្រងឯកសារស្តីពីបទពិសោធលើការអនុវត្តការបង្រៀន និងរៀនពេញមួយថ្ងៃ។

## ២. ការងារពិនិត្យតាមដាន វាយតម្លៃ និងរបាយការណ៍

មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត និងការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាល ក្រុង ស្រុក ខណ្ឌ ត្រូវរៀបចំផែនការពិនិត្យតាមដាន និងវាយតម្លៃមួយច្បាស់លាស់ ធានាបាននូវគុណភាពការបង្រៀន និងរៀនការកំណត់បាននូវវឌ្ឍនភាពការសិក្សារបស់សិស្ស បញ្ហាប្រឈម ដំណោះស្រាយ ជាមូលដ្ឋានសម្រាប់ការធ្វើការកែលម្អ ក្នុងការអនុវត្តការបង្រៀននិងរៀនពេញមួយថ្ងៃ។ គណៈគ្រប់គ្រងសាលារៀន និងគ្រូបង្រៀន ត្រូវធ្វើស្វ័យវាយតម្លៃសាលារៀនឱ្យបាន ២ដងក្នុងមួយឆ្នាំ (ដើមឆ្នាំសិក្សា និងដំណាច់ឆ្នាំ)ដោយប្រើប្រាស់ស្តង់ដាសាលារៀនគំរូ ដើម្បីប្រៀបធៀបលទ្ធផលសម្រេចបានទៅនឹងចំណុចដៅនៃផែនការប្រចាំឆ្នាំ និងរៀបចំបញ្ជីឈ្មោះគ្រឹះស្ថានមធ្យមសិក្សាដែលបានអនុវត្តផ្ញើមកក្រសួងអប់រំ យុវជន និងកីឡានាយកដ្ឋានមធ្យមសិក្សា) (ចំណេះទូទៅ។

ទទួលបានសេចក្តីណែនាំនេះ ប្រធានមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាល ក្រុង ស្រុក ខណ្ឌ គណៈគ្រប់គ្រងសាលារៀន ត្រូវអនុវត្តឱ្យមានប្រសិទ្ធភាពខ្ពស់។

ថ្ងៃព្រហស្បតិ៍ ៥រោច ខែ កត្តិក ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

រាជធានីភ្នំពេញ ថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៥

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

បណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន**

**កន្លែងទទួល៖**

- រដ្ឋបាលរាជធានី ខេត្ត
- ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី
  "ដើម្បីជូនជ្រាបជាព័ត៌មាន"
- មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត
- គ្រប់គ្រឹះស្ថានសិក្សាសាធារណៈ
- អង្គភាពពាក់ព័ន្ធ
  "ដើម្បីអនុវត្ត"
- កាលប្បវត្តិ
- ឯកសារ នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ